ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

TCG26011483138

លេខ......១៥៣៦......អពដ

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៦
Phnom Penh, 15th Jan 2026

# អគ្គនាយកដ្ឋានពន្ធដារ
# GENERAL DEPARTMENT OF TAXATION

## វិញ្ញាបនបត្រ
## អនុលោមភាពសារពើពន្ធ

(ប្រកាសលេខ ១៥៣៦ សហវ.ប្រក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦)

អគ្គនាយកដ្ឋានពន្ធដារបញ្ជាក់ថា ៖

ឈ្មោះក្រុមហ៊ុន ៖ **អ៊ី អេហ្វ ជី ( អិចប្រេស ហ្វូដ គ្រុប )**

លេខអត្តសញ្ញាណកម្មសារពើពន្ធ ៖ **L001-100099718**

ស្ថិតក្រោមការគ្រប់គ្រង ៖ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ    កាលបរិច្ឆេទធ្វើបច្ចុប្បន្នភាព ៖ ២១ មិថុនា ២០១៦

សកម្មភាពអាជីវកម្ម ៖ អាហារ័ណ នីហារ័ណ (គ្រឿងផ្សំ និងគ្រឿងបរិក្ខារសម្រាប់ផលិតអាហារ)

អាសយដ្ឋាន ៖ #៣២១ ជាន់ ទី៧ ផ្លូវ ម៉ៅសេទុង សង្កាត់ ផ្សារដេប៉ូទី ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ

ទទួលបានកម្រិតអនុលោមភាពសារពើពន្ធប្រភេទ ៖ **មាស**

មានសុពលភាពរយៈពេល **២ ឆ្នាំ** សម្រាប់ឆ្នាំជាប់ពន្ធ ២០២៦ ដល់ ឆ្នាំ២០២៧។

## CERTIFICATE OF TAX COMPLIANCE

(Prakas No 1536 MEF/PK dated 23rd December 2016)

GENERAL DEPARTMENT OF TAXATION certifies that :

Company's name : **EFG (EXPRESS FOOD GROUP) CO., LTD.**

Tax Identification Number (TIN) : **L001-100099718**

Under : Department of large Taxpayers    Date of Information Update : 21 Jun 2016

Business activity(ies) : Import Export (ingredients and equipment for food production)

Tax Compliance Type awarded : **GOLD**

Validity period of **2 years** for the tax year of **2026** and **2027**.

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

Minister Attached to the Prime Minister
Delegate of the Royal Government
in charge as Director General of General Department of Taxation

**គង់ វិបុល**

<u>ចម្លងជូន÷</u>
- នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- អង្គភាពសវនកម្មពន្ធដារពិសេស
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
លេខ......៤៤៩..........អពដ.នកទ

L20260112O175TD2866

ថ្ងៃព្រហស្បតិ៍ ១២រោច ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០២៦

## ជម្រាបជូន
## លោក-លោកស្រីនាយក

ឈ្មោះសហគ្រាស ៖ អ៊ី អេហ្វ ជី (អិចប្រេស ហ្វូដ គ្រុប)
ជាអក្សរឡាតាំង ៖ EFG ( EXPRESS FOOD GROUP ) CO., LTD.
លេខអត្តសញ្ញាណកម្ម ៖ L001-100099718 ចុះបញ្ជីនៅ ៖ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
អាសយដ្ឋាន ៖ ផ្ទះលេខ ៣២១ ផ្លូវ ម៉ៅសេទុង សង្កាត់ផ្សារដេប៉ូទី ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

**កម្មវត្ថុ៖** ការជូនដំណឹងអំពីលទ្ធផលនៃការវាយតម្លៃចំណាត់ថ្នាក់អនុលោមភាពសារពើពន្ធ។

**យោង** ៖ -ប្រកាសលេខ ១៥៣៦ សហវ.ប្រក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពី ចំណាត់ថ្នាក់អនុលោមភាពសារពើពន្ធ
-សារាចរលេខ ០០៧ សហវ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពី អត្ថប្រយោជន៍ទទួលបានពីការវាយតម្លៃចំណាត់ថ្នាក់អនុលោមភាពសារពើពន្ធ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូន លោក-លោកស្រីនាយកសហគ្រាស ជ្រាបថា គណៈកម្មការវាយតម្លៃចំណាត់ថ្នាក់អនុលោមភាពសារពើពន្ធបានពិនិត្យយ៉ាងហ្មត់ចត់ទៅលើ ឯកសារយោង និងសាវតារនៃការអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់សហគ្រាសលោក-លោកស្រី។

ជាលទ្ធផល សហគ្រាសលោក-លោកស្រី ត្រូវបានគណៈកម្មការវាយតម្លៃចំណាត់ថ្នាក់អនុលោមភាពសារពើពន្ធសម្រេចវាយតម្លៃផ្តល់ជូនចំណាត់ថ្នាក់អនុលោមភាពប្រភេទ មាស។

ទន្ទឹមនឹងនេះ លោក-លោកស្រីនាយកសហគ្រាស ត្រូវបន្តអនុវត្តឱ្យបានម៉ឺងម៉ាត់នូវកាតព្វកិច្ចសារពើពន្ធនានា ស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។ អគ្គនាយកដ្ឋានពន្ធដារ រក្សាសិទ្ធិក្នុងការដកហូតវិញ្ញាបនបត្រ និងមោឃភាពអត្ថប្រយោជន៍នានាដែលបានផ្តល់ជូនព្រមទាំងទទួលរងពិន័យ និងទោសទណ្ឌផ្សេងៗទៀត ក្នុងករណីមានការរកឃើញថា សហគ្រាសលោក-លោកស្រី ពុំបានអនុវត្តកាតព្វកិច្ចសារពើពន្ធឱ្យបានខ្ជាប់ខ្ជួនស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារនោះទេ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រីនាយកសហគ្រាស អនុវត្តតាមការសម្រេចនេះ។

សូម លោក-លោកស្រីនាយកសហគ្រាស ទទួលនូវសេចក្តីរាប់អាន ពីខ្ញុំ

**ប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ**

**អៀម រដ្ឋា**